ការសម្ភាសរបស់ទ្រា ឈឿន ឆេង

ក៖អ្នកសម្ភាសឈ្មោះ កុយសុភី ខ៖អ្នកត្រូវគេសម្ភាសឈ្មោះ ឈឿន ឆេង

ពត៌មានសង្ខេបរបស់ទ្រា ឈឿន ឆេង

ទ្រាឈឿន ឆេងមានអាយុ៦៧ឆ្នាំ កើតនៅក្នុងឆ្នាំរោង ខែមេយតូច នៅក្នុងឆ្នាំ១៩៥២។ ទ្រាមានបងប្អូន៦នាក់ កាលពីនៅកុមារភាព ទ្រាមានចូលរៀនសូត្រនៅសាលាវត្ត បានត្រឹមថ្នាក់ទី១០ ហើយបានបួសរៀនសូត្រ។

ទ្រាបានរៀបការនៅអាយុ២៥ដោយឱពុកម្តាយជាអ្នករៀបចំអោយតាមផ្លូវច្បាប់ នៅឆ្នាំ១៩៧៩ មកដល់ពេលឥឡូវទ្រាមានកូនចំនួនពានាក់។

ក៖ ចាស! ខ្ញុំជំរាបរលឹកទ្រា តើទ្រាសព្វថ្ងៃសុខសប្បាយនោះទេហេសទ្រា?
ខ៖ បាទ! សុខសប្បាយនោះទេក្មួយ!
ក៖ ខ្ញុំឈ្មោះកុយសុភីបានមកជួបទ្រា!
មានគោលបំណងសុំការអនុញ្ញាតសម្ភាសនៅឆ្នាំកុរឯកស័ក២៥៦២ ខែពិសាខ ៧កើត ត្រូវនឹងថ្ងៃសុក្រទី១០ ខែឧសភា ឆ្នាំ២០១៩ ។នាមត្រកូលទ្រាឈ្មោះអ្វី?
ខ៖ ឈ្មោះ ឈឿនឆេង!
ក៖ តើឈ្មោះហ្នឹងអ្នកណាជាអ្នកដាក់ឈ្មោះអោយ?
ខ៖ ឈ្មោះ ឈុន ឆេង!
ក៖ តើឈ្មោះហ្នឹងមានអត្តន័យយ៉ាងម៉េច?
ខ៖ អត្តន័យគឺថាឈ្មោះហ្នឹងគឺឈ្មោះល្អបានជាគាត់ដាក់អោយនុងណា។
ក៖ តើសព្វថ្ងៃនេះ ទ្រាមានឈ្មោះហៅក្រៅ១ទៀតដេស?
ខ៖ អត់មាននោះទេមានតែឈ្មោះហ្នឹងក្មួយ។
ក៖ អើ!ទ្រាកើតនៅថ្ងៃខែឆ្នាំណា?
ខ៖ នៅថ្ងៃអាទិត្យខែមេយតូច
ក៖ ឆ្នាំ?
ខ៖ នុងឆ្នាំបារាំង!
ក៖ ចាស
ខ៖ ឆ្នាំមិនចាំទេ!
ក៖ ឆ្នាំរោងហេសទ្រា?
ខ៖ ខែមេយតូច ឆ្នាំរោង!
ក៖ ឆ្នាំមួយពាន់ប្រាំបួនរយប៉ុន្នាន?
ខ៖ អានុងឆ្នាំបារាំងនោះទេ!
ក៖ ចាសបើសិនជាចាំឆ្នាំនុងក៏បានដែរ!
ខ៖ ឆ្នាំមិនបានដឹងទេ!
ក៖ ហើយទៅត្រិះស័ករាជនៅឆ្នាំ១៩៥២?
ខ៖ បើសិនជាត្រិះស័ករាជ ឆ្នាំ១៩៥២!
ក៖ អូ! តើទ្រាមានសញ្ជាតិជាអ្វី?
ខ៖ សញ្ជាតិខ្មែរ!
ក៖ កាន់សាសនាអ្វី?
ខ៖ កាន់សាសនាព្រះពុទ្ធ!
ក៖ ចុះមានទីកន្លែងកើតកំណើតនៅក្នុងភូមិ?
ខ៖ កន្លែងកំណើតកើតនៅក្នុងភូមិកំពង់សំណាញ់ នៅឃុំមៀនស្រុកព្រៃឈរ នៅខេត្តកំពង់ចាមយើងហ្នឹង។
ក៖ ចាសរួចចុះនាមត្រកូលឱពុកទ្រាតើមានឈ្មោះអ្វី?
ខ៖ នាមត្រកូលឈ្មោះឱពុក! អីផែនឈឿន។
ក៖ សព្វថ្ងៃនេះគាត់នៅរស់ឬក៏គាត់ស្លាប់?

ខ៖ គាត់ស្លាប់ជាត់ទៅហើយ!
ក៖ ចុះការគាត់ស្លាប់នៅអាយុប៉ុន្មាន?
ខ៖កាលដែលគាត់ស្លាប់នៅអាយុ៥៩កាលនុង។
ក៖ អូ!នេះដែរ ចឹងគាត់ស្លាប់ដោយសារអ្វីដែរទ្រា?
ខ៖ គាត់កើតរោគ!
ក៖ ដោយសារជំងឺហ?
ខ៖ ដោយសារជំងឺរោគពាត!
ក៖ អឹម
ខ៖ រោគារបស់គាត់នុង កាលនុងគាត់កើតទាទឹកពេលនុង។
ក៖ អឹម! ហ៊ីស! តើគាត់មានអត្តចរិកយ៉ាងម៉េចដែរឪពុកនុង?
ខ៖ គាត់មានអត្តចរិកស្លូតបូតនោះទេ! គាត់មានទៅ!
ក៖ អូ ចឹងចុះមុខរបររបស់គាត់ធ្វើអ្វី?
ខ៖ នៅខាងនុងរកត្រីគាត់!
ក៖ រកត្រី!
ខ៖ រកត្រីមុខរបរគាត់! មុខរបរនេសាទត្រី!
ក៖ ចឹងចុះសញ្ជាតិរបស់គាត់ជាអ្វីដែរ?
ខ៖ សញ្ជាតិខ្មែរ!ដែរ!
ក៖ គាត់កាន់សាសនា?
ខ៖ សាសនាព្រះពុទ្ធដែរនុង!
ក៖ ចុះទីកន្លែងរបស់គាត់កើតនៅកន្លែងណា?
ខ៖ សាសនារបស់គាត់នៅព្រះពុទ្ធដែរនុង។
ក៖ ចាស!
ខ៖ នៅកំពង់ស្រណាញ់!
ក៖ ចឹងបងប្អូនខាងឪពុកទ្រាបង្ហើតៗនោះ មានឈ្មោះដូចជាបងគេទី១ឈ្មោះអ្វី?
ខ៖ បងគេទី១ឈ្មោះ ព្រំព្រៀន!
ក៖ ភេទប្រុសហេស?
ខ៖ ភេទប្រុស!
ក៖ ចឹងសព្វថ្ងៃនេះគាត់នៅរស់?
ខ៖គាត់ស្លាប់អស់ហើយ!
ក៖ ហើយចុះទី២ តើគាត់មានឈ្មោះអ្វី?
ខ៖ អី!ឈ្មោះ ព្រំឈឿន តែគាត់មានឪពុកចុងឈ្មោះ ផេន ឈឿនវិញ។
ក៖ អូចឹងគាត់!
ខ៖ គាត់មានឪពុក២
ក៖ចុះហើយបន្ទាប់មកទៀត! តើអស់ហើយហេស?
ខ៖ អស់ហើយតែ២នាក់ហ្នឹង!
ក៖ ចុះនាមត្រកូលម្តាយរបស់ទ្រាវិញឈ្មោះអ្វី?
ខ៖ ឈ្មោះ ទឹមហ៊ីម។
ក៖សព្វថ្ងៃនេះគាត់ស្លាប់នៅ?
ខ៖ គាត់ស្លាប់អស់ហើយ!
ក៖ តើគាត់ស្លាប់នុងនៅអាយុប៉ុន្មានដែរ?
ខ៖ គាត់ស្លាប់នុងប្រហែលជានៅអាយុ៧០ជាង ប្រហែលជា៧៣អី។
ក៖ តើគាត់ស្លាប់នុងដោយសារអ្វីដែរ?
ខ៖ ដោយរោគ!
ក៖ តើអត្តចរិករបស់គាត់នុងយ៉ាងម៉េចដែរ?
ខ៖ អត្តចរិករបស់គាត់ស្លូតបូតនោះទេគាត់មានទៅអីនោះទេ។
ក៖ ចឹងគាត់មានសញ្ជាតិអ្វី?
ខ៖គាត់មានសញ្ជាតិខ្មែរដែរ។

ក៖ ចុះគាត់កាន់សាសនាអ្វី?
ខ៖សាសនាព្រះពុទ្ធដូចគ្នា!
ក៖ ចុះមុខរបររបស់គាត់ធ្វើអ្វី?
ខ៖ គាត់មុខរបររបស់គាត់ក៏គ្មានធ្វើអីនោះទេ! គាត់ចាំផ្ទះមើលផ្ទះ! សំបែងហ្នឹងជាមេផ្ទះ។
ក៖ ចុះទីកន្លែងកំណើតរបស់គាត់?
ខ៖ នៅឯនុងជា១នឹងគ្នានៅឯកំពង់សំណាញ់ហ្នឹង!
ក៖ ចាសចុះការរៀបអាពាហ៍ពិពាហ៍របស់គាត់
តើគាត់ដែរដំណាលនិយាយប្រាប់ដល់ទ្រាដែស?
រៀបតាមចាស់ទុំឬក៏តាមចិត្តរបស់គាត់?
ខ៖គាត់រៀបតាមចាស់ទុំ តាមប្រពៃណី
ក៖ អូចាស! កាលពីដើមរៀបតាមប្រពៃណីចូលទ្រាបកស្រាយ
តើកាលពីដើមគេរៀបដូចយ៉ាងមេចខ្លះ?
ខ៖ កាលពីដើមគេរៀបដូចជាយើងសម័យចឹងដែរមានកាត់សក់
មានអីជាធម្មតាដូចតែគ្នាហ្នឹង។
ក៖ ដូចថាប៉ុន្តែសាមីខ្លួនទាំង២នាក់មានដែរបានស្គាល់គ្នា មានស្គាល់ចិត្តគ្នា
និយាយគ្នាមុន ផ្តោះផ្តងស្នេហាមុនឬក៏គាត់អត់មានបាននិយាយនោះទេ
ស្រាចតែចាស់ទុំគាត់រៀបអីចឹង?
ខ៖ ហេស! គាត់ស្រេចតែតាមចាស់ទុំ ម្តាយឪគាត់រៀបចំទុកដាក់អោយ។
ក៖ ចឹងហេស?ចឹងនេះគេហៅថាតាមប្រពៃណីខ្មែរហើយនេស?
ខ៖ អឺ!
ក៖ ចឹងប្រពៃណីខ្មែរយើងហ្នឹងអាហ្នឹងហើយហេសទ្រាកាលពីដើម?
ខ៖ អើ!
ក៖ ចឹង បងប្អូនខាងម្តាយបង្កើតៗ តើមានឈ្មោះដូចជាបងទី១?
ខ៖ បងទី១ឈ្មោះ ទឹមសៀង!
ក៖ ភេទ?
ខ៖ ភេទស្រី!
ក៖ ទី២?
ខ៖ ទី២ឈ្មោះ ទឹមហៀម!
ក៖ ភេទ?
ខ៖ ក៏ភេទស្រីដែរ! ដល់ទី៣ទឹម
ហៀបហ្នឹងដល់ទី៤ប្រុសទឹមហ្ន១អស់ហើយ!មានតែ៤នាក់ហ្នឹង!
ក៖ ចាស! តើទ្រាកាលពីនៅពីកុមារាណា តើបានចូលសិក្សាដេស?
ខ៖ បានចូលសិក្សារៀននៅសាលាវត្ត!
ក៖ចឹងអត់មានសាលាដូចជាយើងនេះឥឡូវនោះទេ?
ខ៖ អត់មាននោះទេ! រៀននៅសាលាវត្ត!
ក៖ ចឹងរៀននៅក្នុងសាលាឆាន ជាមួយលោកនេនអីចឹងទៅ?
ខ៖ នេះសាលាវត្តនៅសាលាយើងហ្នឹង!
ក៖អឹម! រៀនត្រឹមថ្នាក់ទីប៉ុន្ម្នានដែរទ្រាបានចប់?
ខ៖ អឺ! បានរៀនកាលពីដើមត្រឹមថ្នាក់ទី១០។
ក៖ កាលនុងតើរៀននុងគេបានហៅសាលាអ្វីគេទ្រា?
ខ៖ គេបានហៅថាវត្តកំពង់សំណាញ់!
ក៖ នៅវត្តកំពង់សំណាញ់ហ៎! រួចកាលរៀននុងគ្រូបង្រៀននុងគី?
ខ៖ លោក! មិនមែនជាប្រសក់នោះទេ!
ក៖ ចាសលោកនោះទេជាអ្នកបង្រៀន!
ខ៖ គ្រូលោក មិនមែនគ្រូប្រសក់នោះទេ។
ក៖ អូក៏ប៉ុន្តែគ្រូអ្នកបង្រៀននុង តើលោককាចឬក៏ស្លូត?

ខ៖ លោកដូចជាមិនសូវជាកាចប៉ុន្មានទេ ដូចជាស្លូតដែរនោះទេ!
ក៖ ហឹម! ហើយទៅទ្រាបញ្ចប់ការសិក្សាហ្នឹងទៅ
តើមូលហេតុអ្វីបានបញ្ចប់ដោយសារតែមូលហេតុអ្វី?
ខ៖ មូលហេតុនុងមាន គឺថាអត់មានលុយទៅរៀននៅខាងក្រៅហាស!។
ក៖ ចឹងដោយសារសាលានៅឆ្ងាយ !ចឹងអត់មានលុយទៅអីទៅរៀនតទៀតហេស?
ខ៖ អើ! កាលពីដើមនុងកុំអីគឺបាននៅរៀននៅសាលាអូដាយើងនេះ។
ក៖ ចាសចឹងទ្រាកុំអីបានចូលរៀនត !
ខ៖អើមឆ្ងាយណាស់!
ក៖ចឹងដោយសារតែកត្តាទី១គឺជីវ:ភាពខ្វះខាត ហើយកត្តាទី២គឺសាលានៅឆ្ងាយ។
ដល់ពេលទ្រាឈប់ពីការសិក្សាហ្នឹងទៅទ្រាទៅធ្វើការងារអ្វី?
ខ៖ ពេលដែលបានឈប់ពីការសិក្សារហ្នឹងទៅបានទៅបួស។
ក៖ អូចឹងទ្រាបានបួស!
ខ៖ បាទ!
ក៖ដល់ចឹងទ្រាបានចាប់ផ្តើមមុនដំបូងបួស! គេហៅថាបួសជាអ្វីគេ?
ខ៖ បួសជាសាមេនេ! បួស!ដំបូង។
ក៖ ចាសបួសជាសាមេននុងបានរយ:ពេលប៉ុន្មានដែរ?
ខ៖បានរយ:ពេលបាន៤ព្រះវស្សាដែរ!
ក៖ ចាសចឹង៤វស្សាហើយបានទ្រាទៅបួសហើយបានបួសអីគេបន្តទៀត?បួសផឹក?
ខ៖ បួសផឹក!
ក៖ បួសផឹកនុង! បានប៉ុន្មានទៀត?
ខ៖ អត់មានបានបួសផឹកនោះទេ គឺបានតែបួសនេន បួសជាសាមេននោះទេ។
ក៖ អូចឹងបានតែបួសជាសាមេននោះទេហ៎
បានតែ៤ឆ្នាំហ្នឹងនោះទេហើយសឹកទៅ?
ខ៖ អើ!
ក៖ ដល់ពេលទ្រាបានសឹកចឹងទៅ
តើទ្រាមានបានបន្តធ្វើការងារអ្វីបានបន្តទៀត?
ខ៖ អត់មានបានធ្វើការងារអ្វីទៀតនោះទេ!
រកតែរបបនេសាទត្រីនិងធ្វើត្រីអីបានបន្ដិចបន្ដួច។
ក៖ តែជាមួយនឹងឪពុកនុងនេស?
ខ៖ តែជាមួយនឹងឪពុកម្តាយនុងទៅ!
ក៖ អូចាស! ចឹងឪពុកម្តាយនុងគាត់ធ្វើស្រែចំការនឹងរកត្រី?
ខ៖ ហ្នឹង!
ក៖ ចឹងទ្រារកត្រីកាលនៅពីក្មេងជាមួយនឹងឪពុកហ្នឹង តើត្រីនៅជំនាន់នុង
ហើយមកដល់ជំនាន់នេះតើមានការខុសគ្នាយ៉ាងដូចម្តេច?
ខ៖ អឹម! កាលនៅម៉ាជំនាន់នុងហើយបានមកដល់ឥឡូវនេះគឺមានការខុសគ្នា
ត្រីសំបូរណាស់ បើសិនជាដាក់លបចោលនោះក៏បានត្រីស៊ីដែរ។
ក៖ ចឹងមិនចាំបាច់ទៅដាក់ គេហៅថា!
ខ៖ មិនបាច់ដាក់ព្រួលអីនោះទេ! អើ!
ក៖ មិនបាច់ទេចឹងគ្រាន់តែត្រលាក់លបនុងចូលនៅក្នុងទឹកក៏វាចូលដែរ?
ខ៖ អើ!
ក៖ចឹងសំបូរមែនទែនណ៎!ចឹងចំការការធ្វើស្រែ
ចឹងកាលនុងមានតែការធ្វើស្រែនុងតើទ្រាធ្វើតែស្រែតើហេស
អត់មានដាំដំណាំអីផ្សេងទៀតនោះទេទ្រា?
ខ៖ អត់នោះទេ! ធ្វើដែរ តែស្រែប្រាំង។
ក៖ ចឹងស្រែនុង តើកាលនុងប្រើជីប្រើអីដូចយើងហ្នឹងអត់?
ខ៖ កាលពីដើមអត់មានប្រើជីប្រើអីនោះទេ។
ក៖ ចឹងប្រើជីអ្វីចឹង?

ខ៖ ប្រើជីអាចម៍គោអីនុង!
ក៖ ប្រើតែអាហ្នឹង!
ខ៖ អើ
ក៖ អឺមចឹងទឹកអីគ្រាប់ក្រាន់អីដែរនៅកាលនុង?
ខ៖ ទឹកមានរហាត់! អត់មានម៉ាស៊ីនមានអីនោះទេកាលនុង។
ក៖ អត់មានម៉ាស៊ីននោះទេ! ចឹងអត់មានម៉ាស៊ីនប៊ីមដូចជានៅពេលឥឡូវ?
ខ៖ មានតែអារហាត់រ៉ែនុង។
ក៖ ហឹម!ចឹងហ៎ាស! បើសិនជាធ្វើទៅដែលជួបប្រទះដូចថាស្តុក
ទឹកជំនន់អីដែសដែលបានជួបដែលទ្រាកាលនៅពីក្មេងនុង?
ខ៖ ដូចជាអត់មានបានប្រទះរឿងទឹកជំនន់អីនោះទេ អត់មាន។
ក៖ ចឹងស្រូវជ្រាំងណ៎?
ខ៖ ហ្នឹងហើយ!
ក៖ ហើយចុះស្តុក់អីនោះក៏អត់មានដែរ?
ខ៖ អត់មាននោះទេ!
ក៖ អឺម! ចឹងកាលនុងទ្រាដូចថាកត្តាជីវ:ភាព
កាលធ្វើស្រែចំការនុងចេះតែបានអំណោចផលមកគ្រាប់ក្រាន់ដេសទ្រា?
ខ៖ អើ! វាបានមួយគ្រាប់ក្រាន់ដែរនៅកាលនុង។
ក៖ បានម៉ាហ្គូបៗ!
ខ៖ អើ! ម្ហូបម្ហាអីនុងបានរកស៊ីខ្លួនឯងចឹងទៅស្រែអង្ករអីរកស៊ីដោយខ្លួនឯង។
ក៖ចឹងដូចត្រីអីនុងដូចសំបូរអីចឹងទៅណាទ្រា?
ខ៖ អើ!
ក៖ ចឹងដូចថាបាននៅសល់លុយអី?
ខ៖ អត់មាននោះទេ១
ក៖ អត់មាននោះទេ!
ខ៖ អើ!
ក៖ ហើយដល់ទៅទ្រាមានបងប្អូនចំនួនប៉ុន្មាននាក់?
ខ៖ មានបងប្អូនចំនួន៥ទៅ៦នាក់!
ក៖ តើបងគេមានឈ្មោះអ្វីទ្រា?
ខ៖ បងគេឈ្មោះនុង ឈឿន ឆេងនុងហើយ។
ក៖ ចឹងទ្រាបងគេនុងហេស?
ខ៖ ហ្នឹងហើយ!
ក៖ ចុះដល់ពេលមកទី២តើមានឈ្មោះអ្វី?
ខ៖ ឈ្មោះថា ឈឿន ឆិន!
ក៖ ចាស!ភេទប្រុសហេស?
ខ៖ ភេទប្រុស!
ក៖ តើគាត់ឥឡូវនៅរស់ឬក៏ស្លាប់?
ខ៖ សព្វថ្ងៃនៅរស់នៅទេនៅរស់!
ក៖តើគាត់សព្វថ្ងៃនៅឯណា?
ខ៖ នៅស្រុកកំណើតខាងកំពង់សំណាញ់នុង!
ក៖ ចឹងនៅស្រុកកំណើតណ៎?
ខ៖ អើ
ក៖ ចាសដល់ពេលមកទី?
ខ៖ ទី៣ឈ្មោះ ឈឿនរ៉ែន!
ក៖ភេទ?
ខ៖ ភេទស្រី!
ក៖ គាត់នៅរស់ហេសឥឡូវ?
ខ៖ នៅរស់!

ក៖ គាត់នៅឯណាដែរ?
ខ៖ នៅបឹងកំពង់សំណាញ់នុងដែរ។
ក៖ ចឹងហេស! ចាសហើយដល់ពេលមកទី៤?
ខ៖ ទី៤ឈ្មោះ ឈឿន ឆាយ!
ក៖ ភេទប្រុស?
ខ៖ ប្រុស!
ក៖ នៅរស់?
ខ៖ នៅរស់!
ក៖ចុះស្រុកកំណើត?
ខ៖ ស្រុកកំណើតនៅឯហ្នឹងដែរ ខាងប្រងូរនេះ ។
ក៖ នៅប្រងូរស្រុកកងមាសនេះរិញហេសទ្រា?
ខ៖ ហ្នឹងហើយនៅស្រុកកងមាស!
ក៖ ហើយចុះទី៥?
ខ៖ ទី៥ ឈឿន ហឿន!
ក៖ ភេទ?
ខ៖ ភេទស្រី!
ក៖ ចុះមកដល់ពេលសព្វថ្ងៃនេះតើគ់ាតនៅឯណា?
ខ៖ មកដល់ពេលសព្វថ្ងៃនេះគាត់បាននៅឯខាងកំពង់សំណាញ់ហ្នឹងដែរនុង។
ក៖ចាស
ខ៖ អើ!
ក៖ ហើយអស់នៅទ្រា?
ខ៖ ទី៦ឈ្មោះថាឈឿន ថៃ!
ក៖ ភេទ?
ខ៖ ភេទប្រុស១
ក៖ សព្វថ្ងៃគាត់នៅឯណា?
ខ៖ នៅឯជាមួយនឹងគ្នាទាំងអស់ហ្នឹង!បងប្អូននៅជាមួយនឹងគ្នាទាំងអស់!
ក៖ ចឹង!អូ!....ហើយចុះទី៧?
ខ៖ អស់ហើយបងប្អូនមានតែត្រឹម៦នាក់ហ្នឹងនោះទេ។
ក៖ចឹងបានចប់ត្រឹមបងប្អូន៦នាក់ណាទ្រា!ចាស! ហើយមកដល់ទ្រា
ដូចជាមានអាយុប៉ុន្នានបានទ្រាបានរៀបអាពាហ៍ពិពាហ៍?
ខ៖ អាយុបាន២៥បានរៀបចំគ្រួសារ!
ក៖
ចឹងបានមានគ្រួសារ!ចុះកាលរៀបអាពាហ៍ពិពាហ៍កាលនៅសម័យនុងទ្រាដូចថា
បានចូលថ្លៃទឹកដោះកូនស្រីណា តើបានចំនួនប៉ុន្នានដែរទ្រាចាំដែស?
ខ៖ នៅកាលនុងមានឯណាអត់មានណា
កាលនុងបានមកដណ្តឹងនុងអត់មានបានបង្គាប់បញ្ជាណា អត់មាននោះផង។
ក៖ ចឹងហ៉! មកជាមួយនឹងអ៊ីហ្នឹងគាត់អត់មានបានបង្គាប់អីប៉ុន្នាននោះទេ
ចាស់ទុំរៀបផ្សំផ្គុំអោយឬក៏យ៉ាងម៉េចដែរទ្រានៅកាលនុង?
ខ៖ ១ព្រឹក១ថ្ងៃ!
ក៖ចឹង១ថ្ងៃដែរហ៉?
ខ៖ អើ
ក៖ ១ថ្ងៃចាស!
ខ៖កាលនុងនៅម៉ាជំនាន់បានដាច់ប៉ុលពតហើយនុងបានរៀប។
ក៖ ចាស! អូ! ចឹងបានចាំឆ្នាំដែលទ្រាបានរៀបអាពាហ៍ពិពាហ៍នុងនៅឆ្នាំ?
ខ៖ នៅឆ្នាំ១៩៧៩!
ក៖ ចឹងនៅ១៩៧៩!
ខ៖ អើ! នៅក្រោយដាច់ប៉ុលពតនោះ!

ក៖ ចឹងអត់ទាន់មានអី
ដូចថាវានៅខ្វះខាតដូចថាប្រទេសរបស់យើងទើបតែបានងើបពីសង្គ្រាមនេសទ្រា
?
ខ៖ អើហ្នឹងហើយទើបតែងើប!
ក៖ ហើយចឹងទើបទៅបានប្រាប់ចាស់ទុំ
ញ្ញតិមិត្តជិតខាង!បានបន្តិចបន្តួចចឹងទៅបាន១ព្រឹកចឹងទៅចឹងហេសទ្រា?
ខ៖ ហ្នឹងហើយ!
ក៖ ចាស! ហើយចឹងតើទ្រាបាន រៀបអាពាហ៍ពិពាហ៍ហើយ
បានកសាងបានជាគ្រួសារ១ តើទ្រាប្រកបមុខរបរអ្វី ដើម្បីចិញ្ចឹម
ជីវ:ភាពនៅក្នុងគ្រួសារហ្នឹង?
ខ៖ ប្រកបមុខរបរបានចិញ្ចឹមគ្រួសារ! រកនេសាទបន្តិចបន្តួចនិងធ្វើស្រែប្រាំង
តែប៉ុណ្ណឹង។
ក៖ចឹង ហើយការធ្វើស្រែហ្នឹងតើដី ជាដីកេរដំណែលឬក៏ជាដីទ្រា
ដោយកំលាំងទឹកលុយខ្លួនឯងនេះផ្ទាល់?
ខ៖ អឹម! និយាយទៅដីនេះគឺជាដីកាប់រានដោយខ្លួនឯងនេះផ្ទាល់។
ក៖ អូជាដីរាន! ពីបាទបឹងខ្លួនឯងណាទ្រា?
ខ៖ អើ!
ក៖ ចាសរានបានចំនួនបានប៉ុន្នានហិចដែរទ្រា?
ខ៖ អឹម! បានតែមើលនៅកាលនុងបានតែអើ!
១ហិចអីចឹងនៅកាលនុងស្រូវអីកន្លះហិច។
ក៖ ចឹងហើយឥឡូវនៅមកដល់ពេលឥឡូវហ្នឹងណាទ្រា?
ខ៖ នៅមកដល់ពេលឥឡូវហ្នឹង!
ក៖
ហើយដល់ពេលរដ្ឋគេចែកអោយនោះមានបានដែស?មានរដ្ឋគេបានចែកអោយ
ដេស?
ខ៖ បានដែរ!
ក៖ បានប៉ុន្នានដែរនៅកាលនុង?
ខ៖ បានមើល បាន៦ទៅ៧ម៉ែត្រអីបាន១នាក់។
ក៖ ប៉ុន្នានអា!
ខ៖ ៣ម៉ែត្រកន្លះ ក្បាល បានតែ៣ម៉ែត្រកន្លះ១នាក់ហ្នឹង។
ក៖ ក្បាលបាន៣ម៉ែត្រកន្លះ ហើយចុះបណ្តោយបានប៉ុន្នាន?
ខ៖ មិនដឹងជាប៉ុន្នាននោះទេ ដឹងតែវែង!
ក៖ ចឹងតែវែង ចឹងកាលនុងដីដែររដ្ឋាបានចែកអោយនុង
តើទ្រាបានយកទៅធ្វើអី?
ខ៖ បានយកមកដាំពោតដាំអីនុង។
ក៖ ដាំបន្លែហ៉?
ខ៖ ដាំបន្លែ
ក៖ ចាសដល់ពេលដីដែរទ្រាបានរានពីបាទបឹងគឺទ្រាបានធ្វើជាស្រែ?
ខ៖ធ្វើស្រែ!
ក៖ ចា! ចឹងបន្ទាប់មកទៀត កាលធ្វើស្រែរបស់ទ្រា!
បន្ទាប់ពីទ្រាបានរៀបអាពាហ៍ពិពាហ៍ហើយនេះនិងដាំដំណាំអីនេះ
តើពេលនុងដូចថាមានឧបករណ៍សំភារ:មានអ្វីខ្លះ?
ខ៖ កាលធ្វើស្រែនុង?
ក៖ ចាស! តើមានអីគេខ្លះ?
ខ៖ មានអីនៅកាលនុងមានតែម៉ាស៊ីនបូមទឹកពីទំនប់មកដាក់!
ក៖ ទឹកពីណា?
ខ៖ ស្រែទឹកពីចំកែងទួយយើងនេះ!

ក៖ ចឹងអូមានទឹកពេញចឹងហេសនៅកាលនុង?
ខ៖ អើ
ក៖ បង្ហូរពីទំនប់ទៅ?
ខ៖ ពីទំនប់នុងទៅ!
ក៖ អូ! ទឹកពីនុងទៅជាប្រពន្ធទឹក!
ហើយអត់មានដែរថាខ្វះខាតពីហ្នឹងទៅនោះទេហេស?
ខ៖ អត់មានដែរខ្វះខាតអីនោះទេ
ក៖ ហើយចឹងអត់មានការខ្វះខាតអីដូចជានៅពេលឥឡូវនោះទេហស?
ខ៖ អត់ដែលមាននោះ ខ្វះខាតទឹកអីពីទំនប់!
ក៖ ចាសកាលដែលទ្រានៅធ្វើនុងហេស?
ខ៖ អឹម!
ក៖ រួចចំណែកការធ្វើចំការអីចឹងដែរឬក៏យ៉ាងម៉េចដែរទ្រា?
ខ៖ ការធ្វើចំការនុងវា បូមម៉ាស៊ីនអានុងព្រោះអីទឹកវានៅរាងទាប
ទឹកវានៅឆ្ងាយ!
ក៖ ចឹងទ្រាកាលនៅពេលនុងទ្រាមានម៉ាស៊ីនប្រើហើយហេស?
ខ៖ អើ!
ក៖ រួចទៅកាលធ្វើចំការអីនុង តើមានដូចថាគេដាក់
អីថ្នាំអីសំលាប់សត្វល្អិតអីនុងមានដេស?
ខ៖ មកដល់ពេលឥឡូវនេះមាន ថ្នាំដាក់សម្លាប់សត្វល្អិតនោះ! មាន!

ក៖ ប៉ុន្តែកាលទ្រាធ្វើពីមុននុងមកតើមានអត់?
ខ៖ កាលពីធ្វើពីមុនហ្នឹងមកគឺអត់មាននោះទេ។
ក៖ អត់មាននោះទេ!
ខ៖ អត់មានទេ!
ក៖ ចឹងកាលនុងតើទ្រាបានមានទិន្នផលយ៉ាងម៉េចដែរ
អាអត់មានដាក់ថ្នាំសម្លាប់សត្វល្អិតអីនុង តើយ៉ាងម៉េចដែរ ?
តើមានទិន្នផលបានច្រើនដេស?
ខ៖ បានទិន្នផលវាបានមធ្យម វាអត់មានបានច្រើននោះទេ។
ក៖ ចាស!
ខ៖ វាបាន!
ក៖ ហើយច្រើនមានសត្វអីវាស៊ីសំបូរដូចជានៅពេលឥឡូវនេះដេស?
ខ៖ មិនសូវមាននោះទេកាលពីដើម!
ក៖ ចឹងកាលនុងអត់មានសូវនោះទេហេស?
ខ៖ អត់សូវមាននោះទេ!
ក៖ អឹម!
ហើយដល់ពេលក្រោយមកដល់ពេលបច្ចេកទេសគេមានមកដល់ពេលឥឡូវនេះដា
ក់ជីដាក់អីមកគឺមានសំបូរកង្ហរ ហើយនិងសត្វល្អិតអីនុងគឺសំបូរហើយណាទ្រា?
ខ៖ សំបូរ ដូចជាវាកើតតាមថ្នាំហ្នឹងម៉េចនោះទេ១
ក៖ចាសតាមថ្នាំខ្ញុំបានលឺគេនិយាយ!ចឹងណាទ្រា។
ខ៖ អើ!
ក៖ អើ! មកដល់ពេលឥឡូវនេះសំបូរ! តើទ្រាអើបន្តិបន្ទាប់មក
ទ្រាការធ្វើស្រែនិងចំការរបស់ទ្រានឹងតើមានបានជួបដូចថាការលំបាកអ្វីខ្លះ
ចូលទ្រាបកស្រាយការលំបាកហ្នឹងទៅមើល?
ខ៖ ការធ្វើស្រែហ្នឹងហេស?
ក៖ ចាស!
ខ៖ ដូចជាអត់មានលំបាកអីនោះទេ! ទឹកអីក៏មានអីក៏មាន
អត់មានលំបាកអីនោះទេ កាលធ្វើស្រែហ្នឹង។

ក៖ ចឹងតាំងពីពេលមុនមកដល់ពេលឥឡូវនេះទ្រាអត់មានបានលំបាក
អត់ដូចថាប្រទះឆ្នាំណាមួយត្រូវស្គក់ត្រូវរាំ អត់មានបានផលអីណា
តើមានដែរជួបដេស?
ខ៖ ដូចជាអត់មានបានជួបផង!
ក៖ ចុះឆ្នាំហ្នឹងមានបានជួបប្រទះស្គកអីដេសទ្រា?
ខ៖ ដូចអត់អីនោះទេឆ្នាំហ្នឹង!
ក៖ ចឹងទ្រាអត់អីនោះទេ?
ខ៖ អត់អីនោះទេ!
ក៖ រួចចុះដំណាំដាំ តើទ្រាបានដាំដំណាំអីគេខ្លះមកដល់ពេលឥលូវហ្នឹង?
មានដំណាំដូចជា?
ខ៖ មានទៅដាំអី មានដាំតែពោតមានដាំអីនុង!
ក៖ ចាស! ពោតអីនុងយ៉ាងម៉េចដែរទៅ?
ខ៖ អត់មានអីនោះទេ ដាំតែតាំងពីកូនពោត!
ក៖ ចឹងហ៎! ចឹងសព្វថ្ងៃទ្រាជីវ:ភាពរបស់ទ្រាយ៉ាងម៉េចដែរ?
ខ៖ ជីវ:ភាពវាមិនជាបានធូរធាអីណានោះទេ វាបានជាមធ្យម!
ក៖ ចឹងហ៎!
ខ៖ អើ!
ក៖ ចុះទ្រាមានកូនចំនួនបានប៉ុន្មាននាក់?
ខ៖ កូន៣នាក់!
ក៖ កូនបងគេឈ្មោះអ្វី?
ខ៖ ឈ្មោះឆេង ស្រស់!
ក៖ ភេទ?
ខ៖ ភេទប្រុស?
ក៖ ទ្រាមានបានចាំឆ្នាំរបស់គាត់?
ខ៖ ឆ្នាំរបស់វាគឺឆ្នាំមមី!
ក៖ តើឥឡូវគាត់អាយុបានប៉ុន្មានហើយ?
ខ៖ អាយុបាន៤០ជាងហើយដូចជា៤២។
ក៖ ចាស! ហើយចុះកាលនៅពីក្មេងទ្រាមានបានអោយបានចូលរៀនដែស?
ខ៖ អោយបានចូលរៀនដែរបានត្រឹមថ្នាក់ទី៥ទៅទី៦ហ្នឹង។
ក៖
ចាសចឹងនៅពេលនុងទ្រាបានអោយគាត់បានឈប់ដោយសារខ្លួនឯងឬក៏ទ្រាអោ
យគាត់ឈប់?
ខ៖ វាឈប់ដោយខ្លួនឯងនុង។
ក៖ ចាសហើយចឹងមកដល់ពេលឥឡូវគាត់មានប្រពន្ធនៅឯណា?
ខ៖ មានប្រពន្ធនៅឯនោះ ខាងក្លួយ។
ក៖ ប្រពន្ធរបស់គាត់មានឈ្មោះអ្វី?
ខ៖ ប្រពន្ធឈ្មោះអី! ឈ្មោះផល្លា។
ក៖ ចាសចុះគាត់បានកូនប៉ុន្មានហើយនុង?
ខ៖ បានកូន២!
ក៖ ស្រីប៉ុន្មាន?
ខ៖ ស្រី១ប្រុស១
ក៖ ចាសហើយចុះមកកូនទ្រាទី២មានឈ្មោះអ្វី?
ខ៖ ឈ្មោះ ឆេងស្រួល!
ក៖ ភេទ?
ខ៖ ភេទប្រុសដែរ។
ក៖ ហើយចុះឆ្នាំរបស់គាត់ តើមានឆ្នាំអ្វី?
ខ៖ នុងវាឆ្នាំរកា!

ក៖ ហើយចុះឥឡូវហ្នឹងតើគាត់អាយុប៉ុន្មាន?
ខ៖ អាយុ៤១ហើយយ៉ាង។
ក៖
ចាសហើយមកដល់ពេលឥឡូវនេះតើគាត់បានចូលសិក្សាបានត្រឹមកំរិតប៉ុន្មាន?
ខ៖ បានសិក្សាបានត្រឹមថ្នាក់ទី១២
ក៖ អូចឹងគ្រាន់បើ! ចឹងតើមកដល់ពេលឥឡូវនេះតើគាត់បានធ្វើការងារអ្វីដែរ?
ខ៖ អត់មានបានធ្វើការងារអ្វីនោះទេ
គឺថាមកដល់ពេលឥឡូវនេះគឺកាលនុងវាបានប្រឡងធ្លាក់
ប្រឡងអត់បានជាប់ផង។
ក៖ ចឹងប្រឡងធ្លាក់ជាក់ឌុប!ចឹងដល់ពេលប្រឡងធ្លាក់ចឹងទៅក៏ឈប់រៀនទៅ?
ខ៖ ចឹងក៏ឈប់រៀនទៅ!
ក៖ ហើយគាត់ប្រកបទៅរកមុខរបរអ្វី?
ខ៖ វានុងទៅនៅឯភ្នំពេញនោះ វារាល់ថ្ងៃនេះវារកស៊ីរត់ម៉ូតូកង់បីនុង។
ក៖ អូ!ចឹងគ្រាន់បើ ហើយមកដល់ពេលឥឡូវនេះគាត់មានគ្រួសារហើយ?
ខ៖មានហើយ!
ក៖ ឈ្មោះអ្វី?
ខ៖ ឈ្មោះស្រីទុំ
ក៖ ស្រុកកំណើតប្រពន្ធរបស់គាត់នៅឯណា?
ខ៖ ស្រុកកំណើតនៅឯខាងតាកែវ
ក៖ ហើយចុះបច្ចុប្បន្នហ្នឹង តើគាត់បាននៅឯភ្នំពេញហ្នឹងហេស?
ខ៖ ហ្នឹងហើយនៅភ្នំពេញហ្នឹង!
ក៖ ចឹងគាត់បានមានផ្ទះមានអីនៅ?
ខ៖ មានហើយ
ក៖ អូ! ហើយចឹងតើគាត់មានកូនចំនួនប៉ុន្មាន?
ខ៖ កូនមានតែ១នាក់នុង
ក៖ ចឹងកូនតែ១នោះទេ!
ខ៖ អើម
ក៖ ហើយចុះមកដល់កូនទ្រាទី៣មានឈ្មោះអ្វី?
ខ៖ កូនទី៣ឈ្មោះ ឆេងកុសល អឺ!
ក៖ ភេទ?
ខ៖ ភេទប្រុសដែរ!
ក៖ ហើយឆ្នាំ?
ខ៖ ឆ្នាំមមី
ក៖ អាយុប៉ុន្មានហើយ?
ខ៖ អាយុ៣១ហើយ
ក៖ អូ! ចឹងហើយតើគាត់បានចូលសិក្សាបានត្រឹមថ្នាក់ទីប៉ុន្មាន?
ខ៖ បានត្រឹមថ្នាក់ទី៦ហើយឈប់ដែរ។
ក៖ គាត់ឈប់ដោយខ្លួនឯង?
ខ៖ ដោយខ្លួនឯង!
ក៖ ចឹងដល់គាត់ឈប់ទៅ គាត់ទៅប្រកបមុខរបរ?
ខ៖ មុខរបរធ្វើនេសាទត្រីនិងធ្វើស្រែប្រាំងនុង។
ក៖ អូចឹងបានជាមួយនឹងទ្រាហេស?
ខ៖ ហ្នឹងហើយជាមួយនឹងគ្នាហ្នឹង! នៅក្នុងបន្ទុកជាមួយនឹងគ្នាហ្នឹង។
ក៖ ចាសហើយចឹងមកដល់ពេលឥឡូវនេះគាត់មានគូស្រករហើយ?
ខ៖ មានប្រពន្ធហើយ!
ក៖ តើប្រពន្ធមានឈ្មោះអី?
ខ៖ ឈ្មោះកុលាប!

ក៖ កុលាប ហើយស្រុកកំណើតរបស់គាត់នៅឯណា?
ខ៖ ស្រុកកំណើតនៅឯខេត្តសៀមរាបឯណោះ។
ក៖ ចឹងកូនរបស់ទ្រាសុតតែទៅរកប្រពន្ធនៅឆ្ងាយៗ
តើមានមូលហេតុអ្វីបានជាគាត់បានទៅ?
ខ៖
មូលហេតុអានុងវាបានទាក់ទងគ្នាបានទូរស័ព្ទនុងហើយក៏បានមកជ្រាប់ឪពុកម្តាយទាក់ទងអោយចឹងទៅ។
ក៖ អូ
ខ៖
កាលនុងគ្មានឪពុកម្តាយអីទៅទាក់ទងអោយគីវាបានទាក់ទងស្រលាញ់អីដោយខ្លួនវានុង។
ក៖ ចាស! មកដល់ពេលឥឡូវហ្នឹងគេមានកូនចំនួនប៉ុន្មាន?
ខ៖ មកដល់ពេលឥឡូវនេះមានកូនចំនួន២នាក់ហើយមកដល់ពេលឥឡូវ។
ក៖ ចឹងមានកូនបានប៉ុន្មាន?
ខ៖ មានកូនស្រី១នាក់ហើយនិងប្រុសបាន១។
ក៖ ចាស! ចឹងគាត់មកនៅជាមួយនឹងទ្រាបានប៉ុន្មានឆ្នាំហើយកូនហ្នឹង?
ខ៖ អើ! មកនៅជាមួយនឹងបានប្រហែលជា៥ទៅ៦ឆ្នាំហើយ។
ក៖ អឹម ហើយបានបន្ទាប់មកទៀតអស់ហើយកូន?
ខ៖ មានតែ៣នាក់ហ្នឹង!
ក៖ ចាមានតែ៣នាក់ហ្នឹង ចឹងទ្រាសព្ទថ្ងៃនៅជាមួយនឹងកូន
តើទ្រាមើលទៅទឹកចិត្តកូននុងបានទីពឹងទៅមុខអីបានដែរកូនប្រសារនិងកូនបង្កើតហ្នឹង?
ខ៖ បានទីពឹងអីបានតាមមើលទៅទឹកចិត្តរបស់វា។
ក៖ ចាសចឹងកូនប្រសារអីទឹកចិត្តបានដែរអត់អីទេ?
ខ៖ បានដែរ!
ក៖ ចឹងគាត់មានដែរដូចជាពេលរល់បុណ្យទានអីតើគាត់មានដែរ
ទៅលេងផ្ទះម្តាយក្មេងអីដេស?
ខ៖ ទៅ!
ក៖ ម្តាយក្មេកអីកូនស្រស់នេះ?
ខ៖ ទៅ! វាបានទៅលេងម្តាយវានៅខាងស្រុកដែរ។
ក៖ ទៅដូចថាជីវ:ភាពគាត់សព្ទថ្ងៃនេះហ្នឹង តើគាត់មានម៉ូតូអីជិះដែរ?មានដេស?
ខ៖ មានម៉ូតូកញ្ចាស់១
ក៖ ចាសហើយចឹងមកដល់ពេលឥឡូវហ្នឹង តើគាត់បានទៅរកត្រីអីនុង
តើបានច្រើនឬក៏តិច?
ខ៖ អឹម! តិចៗគ្រាន់តែថាបានដោះស្រាយជីវ:ភាពនុងណា។
ក៖ ចឹងតើកូននេះត្រូវចៅទ្រានេះ តើមានបានអោយគេចូលរៀនដេសចឹង?
ខ៖ ចូលរៀនតើ ចូលរៀនសព្ទថ្ងៃហ្នឹងតើ។
ក៖ ចឹងហ៎! បានទាំង២នាក់!
ខ៖ បានតែ១នាក់នោះទេ ចៅ១ទៀតនៅតូចមិនទាន់គ្រាប់អាយុនោះទេ។
ក៖ ចឹងហ៎ មិនទាន់គ្រាប់អាយុចូលរៀន!
ខ៖ មិនទាន់គ្រាប់អាយុបានចូលរៀននោះទេ។
ក៖ ចាសចឹងចៅបងគេនៅបន្ទុកជាមួយនឹងទ្រាហ្នឹង តើឪពុកម្តាយអី
គាត់មានដែរបង្រៀនហើយបង្ហាត់អីពេលយប់ៗអីបង្ហាត់ដេស?
ខ៖ ដែរបង្ហាត់ដែរ
ដូចថានៅពេលយប់ៗអីចេះតែនែលនាំវាអោយយកសៀវភៅមករៀនចឹងណា។
ក៖ ហើយកូននុងមានការយកចិត្តទុកដាក់នៅការសិក្សាហ្នឹងដេស?
ខ៖ វាយកចិត្តទុកដាក់ដែរនុងណាចៅនុង។

ក៖ចឹងហេស! រួចទៅយើញ ដូចថាកូននុងទូរស្សន៍អីមានឧស្សាហ៍មើលអី?
ខ៖ មិនដែរបើកទូរស្សន៍អីមើលណា អត់មានផង។
ក៖ ចឹងអត់មានទូរស្សន៍ទេ?
ខ៖ អត់!
ក៖ ចឹងល្អវិញ!
នេះដែរចឹងកុំអោយវាដិតអាម្មរណ៍ទៅនឹងទូរស្សន៍អត់ខំប្រឹងរៀន។ចាសចឹងប្រពន្ធទ្រាឈ្មោះអ្វី?
ខ៖ ឈ្មោះ ស្រ៊ន់ស្រ៊ីម!
ក៖ ចុះស្រុកកំណើតរបស់គាត់នៅឯណា?
ខ៖ ស្រុកកំណើតរបស់គាត់នៅអូសកណ្ពុរណ៍!
ក៖ នៅអូសកណ្ពុរ! ចាសប៉ុន្នានគាត់ ដូចថាគាត់កើតនេះគាត់រៀងអន់ត្រចៀកធ្ងន់ត្រចៀកចឹងតាំងពីរយៈពេលប៉ុន្នានឆ្នាំហើយមក?
ខ៖ អូ រឿងអន់ត្រចៀកនឹងវាមានកើតតាំងពីច្រើនឆ្នាំមកហើយ។
ក៖ តាំងពីពេលណាមក?
ខ៖ មើលប្រហែលជាបានតាំងពី១០ជាងអីហើយ។
ក៖ រួចចុះតើមានមូលហេតុអ្វីបានជាគាត់រៀងធ្ងន់ត្រចៀកហ្នឹង?
ខ៖ អូកាលនុងឈឺ!
ក៖ អឺ! ចឹងឈឺមុនសិន!
ខ៖ អូ! កាលនុងឈឺឡើងក្អូតៗ ឡើងបែកក្រដាសត្រចៀកព្រោះក្អូតវាអត់ចេញ!
ក៖ អូ! អឺម! ទៅស្តាប់អត់បានតាំងពីពេលនុងមក?
ខ៖ អើ
ក៖ មីងមែង!ៗ ចឹងចូលទ្រា រៀបរាប់ពីអតិកាលតាំងពីនៅក្នុងរបរនុងមកតើនៅពេលនុងគេបានអោយទ្រារស់នៅយ៉ាងដូចម្តេចខ្លះ?
ខ៖ កាលនៅក្នុងរបបប៉ុលពតនុង គឺបបរលាយត្រកួននឹងលាយដើមចេកនុងហើយលាយពោតលាយអីនុងកាលនៅក្នុងជំនានប៉ុលពត។
ក៖ ចុះម្ហូបម្ហាអីនោះ?
ខ៖ ម្ហូបម្ហាអីនុងវាខ្លះខានដែរនុង!
ក៖ អត់ឆ្អែកនោះទេ!
ខ៖ សម្លត្រកួន!
ក៖ ចឹងគេចែកជារបបចឹង!
ខ៖ គេចែកជារបរនៅកាលនុង!
ក៖ អូ
ខ៖កាលនុងគេបានចែកជារបបស្មើៗគ្នា។
ក៖
ចឹងគេមិនមែនថាដូចជាមាឧចាស់គេអោយផ្សេងហើយដល់ពេលធំអីគេអោយផ្សេងនោះទេឬក៏យ៉ាងម៉េច?
ខ៖ របរស្មើៗគ្នារបរ! ស្មើភាពគ្នាទាំងអស់។
ក៖ ហើយចឹងអ្នកដែលដូចថាពិសារវាងច្រើនតិចទៅអត់មានឆ្អែតនោះទេ?
ខ៖ អត់មានឆ្អែតនោះទេ!
ក៖
រួចទៅកាលរស់នៅដូចថាគេអោយគេងអីនោះតើគេបានទៅគេងនៅឯណាដែរទ្រា នៅផ្ទះយើងឬក៏នៅផ្ទះហេសទ្រា?
ខ៖ អើម! នៅកាលនុងគឺក្រុមចល័តគេគេងរួមគ្នាអត់មានគេងនេះណា។
ក៖ ផ្នែកប្រុសៗ!
ខ៖ ផ្នែកប្រុសៗទៅប្រុសៗទៅហើយស្រីៗទៅផ្នែកស្រីៗទៅ។
ក៖ ចឹងចល័តចឹងទ្រា! គេបានអោយធ្វើការងារអ្វី?
ខ៖ គេអោយរែកដីរែកអីនុង។

ក៖ ប្រពន្ធភ្លីស្រែឬក?
ខ៖ គេអោយលើកធ្វើភ្លីស្រែអីនុង លើជាទ្រនុបនិងប្រឡាយនុង។
ក៖ អឹម! ចឹងទី១តើគេចាំអោយទ្រាទៅរែកប្រឡាយនៅឯណា តើទ្រាបានចាំទេ?
ខ៖ រែកទ្រនុបនៅទំនុបនៅតាកុងអីនុង ទំនប់ឡើងគ្រាប់កន្លែង។
ក៖
ចឹងទ្រាបានចាំថាគេបានដាក់ផែនការណ៍អោយទ្រារែកនៅក្នុង១ថ្ងៃបានប៉ុន្មាន?
ខ៖ គេបានអោយរែកនៅក្នុង១ថ្ងៃ៣ម៉ែត្រគីប។
ក៖ ហើយទ្រារែកបានដេស?
ខ៖ អឹម!ប្រើងទាល់តែរួចនុង ហីស!
ក៖ ទំនប់ពីជើងរន្ធនេះមកទំនប់នុងខ្ពស់ណាស់រែកបាន១ជើងៗ?
ខ៖ អឹម! ចេះតែប្រើងទៅ
ព្រោះអីបើសិនជាមិនប្រើងនោះគ្រែលោគេយកទៅធ្វើបាប។
ក៖ ប៉ុន្តែកាលនុងទៅរែកដីនៅការដ្ឋានុងតើគេបានអោយបាយដេសទ្រា?
ខ៖ បានបាយ!
ក៖ ចាសចឹងបានពិសារបាយរាងនឹងពោះបន្ទិច!
បន្ទាប់ពីនុងមកតើទ្រាគេមានបានអោយទៅខាងណាទៀត?
ខ៖ រាគេអោយទៅចល័តឡើងគ្រាប់កន្លែងនុងណា ឡើងចល័តគ្រាប់កន្លែងនុង។
ក៖ អឹម!
ខ៖ នៅកន្លែងណាក៏យើងធ្វើដែរ។
ក៖ ធ្វើដែរ ក៏ប៉ុន្តែចល័តនុងដូចជាការរែកទំនប់ ជីកប្រឡាយ ធ្វើប្រពន្ធភ្លីស្រែ
ជីកប្រឡាយ។
ខ៖ ជីប្រឡាយ លើទំនប់
ក៖ អូ!ប៉ុន្តែសុតតែដាក់កំរិតចឹង?
ខ៖ ៣ម៉ែត្រគីប!
ក៖
ប្រពន្ធភ្លីស្រែគេរែកជា?ដូចជាបណ្តោយនេះវែងតើប៉ុន្មានម៉ែត្រទៅនៅក្នុង១ថ្ងៃ?
ខ៖ អានុងគេរាស់ទៅតាមរែកជាម៉ែត្រគីប។
ក៖ អូចឹងអានុងគេរាស់ម៉ែត្រដែរនុងហេស?
ខ៖ អើ!
ក៖ ចឹងកាលទៅរែកដីទៅរែកអីនុង
ដូចថាទ្រាមានបានឃើញនឹងភ្នែកជាក់ស្តែរឬទេ
ព្រោះអីលឺថាអ្នកដែលគេបានអោយរែកអត់បានតាមតំរូវការរបស់គេនុងគឺមាន
ប្រធានកងគេយកទៅវ៉ែចោលអីចឹងមែនឬក៏យ៉ាងម៉េចដែរកាលនុង?
ខ៖ អើ! អាហ្នឹងវាបានជាន់ស្តែងវាចឹងមែនហើយ។
ក៖ ចឹងទ្រាមានបានដែរបានឃើញនៅនឹងភ្នែកនៅនឹងមុខជាន់ស្តែងទេ?
ខ៖ អត់មានដែរឃើញនោះទេ គេបានធ្វើលួចលាក់។
ក៖ ចឹងទ្រាពេលនុងទ្រាមានបានដែលនឹកបងប្អូនឪពុកម្តាយអីចឹង
ទ្រាអាចទៅសុំមេកងអីទៅលេងបានដេសទ្រា?
ខ៖កាលនុងហេស?
ក៖ ចាស
ខ៖ កាលនុងវាតឹងតែងដែរនុងណា
ពេលយើងទៅវាមិនចង់អោយទៅលេងអីដែរនុង។
ក៖ ចឹងទ្រាបែកពីអី ភូមិកំពង់សំរិតនេះមក
ទ្រាបានមកលើកទំនប់នៅខាងកំពង់ចាមនេះហេសទ្រា?
ខ៖ អើ!
ក៖ ហើយដល់ចំណែកខាងឪពុកម្តាយគឺបាននៅលើកទំនប់ខាងកំពង់សំរិតនោះ
នៅកំពង់សំណាញ់!

ប៉ុន្តែនៅខាងនុងនិយាយទៅច្បាប់រាងធ្ងរជាខាងកងមាសហេស?ឬយ៉ាងម៉េចដែរ
ទ្រា?
ខ៖ មិនធ្ងរនោះទេដូចតែគ្នាហ្នឹង!
ក៖ ខ្ញុំលឺគេថាខាងកងមាសនេះតាំងណាស់!
ខ៖
ខាងនុងក៏សម្លាប់អីដូចតែគ្នាមកនេះក៏សម្លាប់អីបានដូចតែគ្នាហ្នឹងកាលនុង។
ក៖ ចឹងហេស!
ខ៖ នៅកន្លែងណាក៏ដូចកន្លែងណាដែរ។
ក៖ ចឹងនៅក្នុងរបបនុងតើអង្គការនុង តើគេដាក់ដូចថា!
រិនីយតឹងរឹងយ៉ាងម៉េចខ្លះដូចជាសំលៀកបំពាក់ ដូចជាការស្នាក់នៅ!
ស្នាក់អីនុង?
ខ៖ សំលៀកបំពាក់គឺអត់មានពណ៌អីនោះទេ សុតតែខ្មៅទាំងអស់!
សូម្បីតែកម្ពាធីបាលនោះក៏សុតតែខ្មៅដែរ។
ក៖ កម្ពាធិបាលនុងហាន:អ្វី? គេហៅថាហាន:ស្ពើ?
ខ៖ ហាន:ស្ពើនឹងមើលការខុសត្រូវដូចជាមេប្រធានក្រុមហ្នឹង។
ក៖ ចឹងអូ! ចឹងនេះគេហៅថាកម្ពាធិបាលហ៎!
ខ៖ អើ
ក៖ ចាស! ហើយចុះរបបទ្រព្យអីទាំងប៉ុន្ថាន ?
ខ៖ ជារបបសមូហភាពទាំងអស់ អត់មាន១តួនោះទេ។
ក៖ អត់មានតែម្តង!
ខ៖ អត់មានទេ១
ក៖ ចឹងដូចជារបរដែរយើងបានដាំនៅផ្ទះអីចឹង !
ខ៖គេបានដាក់ជារបស់សមូហភាពទាំងអស់។
ក៖ ហើយចុះដល់ពេលយើងឃ្លានចង់សុំ ប៉ះអីយ៉ាងម៉េចដែរ?
ខ៖ អី!បើសិនជាស៊ីដល់គេដឹង គេនេះ គេដាក់អោយជាប់ទាស!
ក៖ ចឹងមិនបាននោះទេចឹង!
ខ៖ ក្ខានទេ ! ក្ខានតួរអីនោះទេនៅកាលនុង!
ក៖ អឹម! ចឹងទ្រាតាំងពីចូលនៅរបបនុងចឹងទៅគេអោយទ្រាទៅរែកដី !!
ហ្នឹងអត់មានផ្លាស់ប្តូរការងារហ្នឹងទៅភ្ជួរដីអីអត់មាននោះទេនៅកាលនុង?
ខ៖អត់មាននោះទេ អត់មានទេ! មានតែរែកដីអីនុងមាន។
ក៖
ចុះទ្រាមូលហេតុអីបានជាទ្រាដឹងថាបានដាច់ពីរបបប៉ុលពតនុង?ដោយសារតែ
បានឃើញសភាពការខុសភ្លែកយ៉ាងម៉េចបានជាទ្រាដឹង?
ខ៖ ដឹងម៉េច ដាច់ពីប៉ុលពតនុងណា!
ក៖ តើសភាការណ៍នៅក្នុងពេលនុងយ៉ាងម៉េច
ដូចជាគេប្រាប់ថាដាច់ប៉ុលពតហើយយើងត្រូវមកផ្ទះចឹងហេស
ឬក៏ដោយសារតែឃើញសភាការណ៍យ៉ាងម៉េចដែរ
ខុសភ្លែកពីធម្មតាយ៉ាងម៉េចដែរ?
បើដូចជារាល់ដងជាធម្មតាគេចេះតែអោយយើងទៅរែកដី
ដល់ពេលគេឈប់អោយយើងទៅរែកដី គេប្រាប់ថាដាច់ពីអាពតនុងហើយ!
ខ៖ នៅកាលនុងដាច់ពីប៉ុលពតនុង គឺបាននាំគ្នាលឺពីខាងពួកកំពង់ចាម
បានលឺសូរថាពួកវៀមណាមចូលមក។
ក៖ លឺកងទ័ពវៀតណាមហេស!
ចឹងទ័ពវៀតណាមបានចូលមកជួយរំដោះចឹងហេស?
ខ៖ ហ្នឹងហើយលឺសំលេងខាងពួកនុងពីកំពង់ចាមមក
ពួកនុងរត់បែកខ្ទែកគ្នានុង។
ក៖សម្លេងអីគេ សម្លេងកាំភ្លើងមែន?

ខ៖ សម្លេងកាំភ្លើងរត់ក្រោះនុង។
ក៖ អូចឹងហើយបាននាំគ្នា! ចារួចទៅបាននាំគ្នា?
ខ៖ នាំគ្នារត់រប៉ាតរប៉ាយទៅកាលនុងហ់។
ក៖ នាំគ្នារត់មកផ្ទះរាងៗខ្លួនចឹងទៅ!
ខ៖ មកៗផ្ទះរាងៗខ្លួនចឹងទៅ!
ក៖ ចឹងដល់ពេលទ្រាបានមកផ្ទះចឹងទ្រាបានជួបឪពុកម្តាយបងប្អូនទេ
មានជុំគ្នា?
ខ៖ ជួប បានជុំគ្នា!
ក៖ ចឹងអត់មានបានបែកសមាជិកឬបានបែកគ្នាទេ?
ខ៖ អត់មានបែកគ្នានោះទេកាលនុង!
ក៖ អូ! អឺស!ដល់ពេលទ្រាថាទើបតែដាច់ដំបូងចឹង
ទ្រាអត់ទាន់មានរបបរបអីឆ្នាំងអីក៏មិនទាន់បានមានចឹងដែរ
ចឹងពេលនុងត្រូវរកវិធីអីបានហូបបាយដាំបាយអីទ្រា នៅពេលដំបូងៗហ្នឹង។
ខ៖ កាលពេលដំបូងនុងគឺថានៅជង្រុកស្រាប់ចឹងទៅ គឺថាបាននៅជង្រុក
ប៉ុលបានធ្វើជង្រុកធំ១ហើយបានរ៉ែជង្រុកនុងបានដណ្តើមស្រូវគ្នាយកមកដាំបា
យស៊ី។
ក៖ ចឹងហេទ្រា?
ខ៖ អើ!
ក៖ ហើយដល់ពេលបានឆ្នាំអីបានទៅយកនៅកន្លែងរួម?
ខ៖ នៅកន្លែងឃ្លាំងគេនុង!
ក៖ ចាស!ចឹងទៅរើយកមកវិញមក?
ខ៖ អើ!
ក៖ អឺម! ចឹងមុននឹងបញ្ចប់តើទ្រាមានពាក្យពេចន៍អ្វីដើម្បីផ្តាំផ្ញើដល់ប្អូនៗ កូនៗ
និងប្អូនៗជំនាន់ក្រោយ?
ខ៖ កូនចៅជំនាន់ក្រោយសូមអោយខំរៀនសូត្រ សូមខំថែរក្សាខ្លួនអោយបានល្អ
តាមប្រពៃណីខ្មែរ!។
ក៖ អឺម!
ខ៖ ហើយអោយខំប្រឹងរកស៊ីតាមអំពើល្អ សុចរិត ត្រឹមត្រូវ។
ក៖ អូ!
ខ៖ ថែរក្សាប្រពៃណីខ្មែរអោយបានល្អ កុំអោយបាត់បង់!
ក៖ប្រពៃណីខ្មែរយើងដូចជាសំលៀកបំពាក់អីចឹងហេសទ្រា?
ខ៖សំលៀកបំពាក់អីនុងកុំអោយស្លៀកខោចលើខោចក្រោម។
ក៖ចាសចឹងសំលៀកបំពាក់ដូចជារៀបអី?
ខ៖ រៀបអាពាហ៍ពិពាហ៍ទៅតាមប្រពៃណីខ្មែរ?
ក៖ ហើយសង្គមគេបំបាត់អ្វី?
ខ៖ បាត់ក្រឿងញៀន!
ក៖ ចាសកុំអោយ?
ខ៖ គេបំបាត់ក្រឿងញៀន
ក៖ ចឹងមានអីគេទៀតទេទ្រាមានអីបន្តទៀត?
ខ៖ អត់មានអីបន្តទៀតនោះទេ
ក៖ ចឹងអស់ហើយហេសទ្រាម?
ខ៖ អត់ហើយមានអីទៀត
ក៖ ចឹងខ្ញុំសូមអរគុណទ្រាជ្រើន
ដែលទ្រាបានខំលះបង់ពេលវេលាអោយក្លួយបានសម្ភាសដឹងអំពីដំណើរ
ជីវ:ភាពរបស់នៅរបស់ទ្រា
តាំងពីដឹងក្តីរហូតមកដល់ពេលបច្ចុប្បន្នហើយខ្ញុំសូមថតរូបទ្រាភ្ជាប់ជាមួយនឹងប
ទសម្ភាសយកទៅចង់ក្រង់ជាពង្សរ:ប្រវត្តិគ្រួសារ ចាស់ៗជំនាន់មុន

ទុកអោយក្មេងៗជំនាន់ក្រោយស្ថិតនៅតាមថែរក្សារបស់សកលវិទ្យាល័យ
BYUនៅUSAតើទ្រាអនុញ្ញាតអោយក្លួយ
យកទៅដាក់នៅលើគេហ:ទំព័រនេះបានដែរឬទេ?
ខ៖ ហាក់! អត់អីនោះទេ!
ក៖ ថាទៅទ្រា!
ខ៖ បានអត់អីនោះទេ យកទៅ!
ក៖
ចឹងខ្ញុំសូមប្រសិទ្ធពរជ័យទ្រាអោយជួបតែពរ៤ប្រការគឺអាយុវណ្ណ:សុខ:ពាល:កុំប្បីឃ្លានឃ្លាតឡើយខ្ញុំអរគុណ! ជំរាបលាទ្រា។
ខ៖ អើ!